**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
លេខ : ៧១៥ / ៥៩៥ ប្រក.សហវ-កសក

# ប្រកាសរួម

## ស្តីពីការកែសម្រួលប្រការ ២ នៃប្រកាស
## លេខ ១២៧៦ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៩
## ស្តីពីការកំណត់ថ្លៃសួយសារឈើឈរឡើងវិញ ដើម្បីបង់ចំណូលថវិការដ្ឋ

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអនុក្រឹត្យទាំងឡាយដែលជំនួស បំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអនុក្រឹត្យទាំងឡាយដែលជំនួស បំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញប្រកាសលេខ ១២៧៦ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការកំណត់ថ្លៃសួយសារឈើឈរឡើងវិញ ដើម្បីបង់ចំណូលថវិការដ្ឋ

-បានឃើញការចាំបាច់

**ស ម្រេ ច**

**ប្រការ១** : ត្រូវបានកែសម្រួលប្រការ ២ នៃប្រកាសលេខ ១២៧៦ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការកំណត់ថ្លៃសួយសារឈើឈរឡើងវិញ ដើម្បីបង់ចំណូលថវិការដ្ឋ ដូចខាងក្រោម :

**ប្រការ២ថ្មី:** ចំពោះសម្បទានដីសេដ្ឋកិច្ចត្រូវធ្វើការវាយតម្លៃប៉ាន់ស្មានធនធានផល អនុផលព្រៃឈើតាមអនុតំបន់ដែលអនុញ្ញាតឱ្យឈូសឆាយជាមុន និងអនុវត្តតាមនីតិវិធីដូចខាងក្រោម :

-ក្រុមហ៊ុនត្រូវដាក់ពាក្យសុំធ្វើការឈូសឆាយតាមអនុតំបន់ដែលបានកំណត់ក្នុងផែនការមេ មកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឱ្យបានយ៉ាងតិចបំផុតក្នុងរយៈពេល ០៤ ខែ មុនកាលកំណត់ចាប់ផ្តើមឈូសឆាយ

-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងពិនិត្យផ្តល់គោលការណ៍អនុញ្ញាតឱ្យឈូសឆាយក្នុងរយៈពេលមិនលើសពីមួយខែ គិតចាប់ពីថ្ងៃទទួលបានពាក្យស្នើសុំរបស់ក្រុមហ៊ុន

-រដ្ឋបាលព្រៃឈើនឹងសហការជាមួយក្រុមហ៊ុនធ្វើការវាយតម្លៃធនធានផល អនុផលព្រៃឈើ ដែលមានក្នុងអនុតំបន់ដែលទទួលគោលការណ៍សម្រេចអនុញ្ញាតឱ្យឈូសឆាយឱ្យចប់ក្នុងរយៈពេល ០៣ ខែ គិតចាប់ពីថ្ងៃទទួលបានការសម្រេចជាគោលការណ៍ឱ្យឈូសឆាយ

-ចំពោះឈើដែលបានមកពីការឈូសឆាយ ក្រុមហ៊ុនត្រូវរៀបចំប្រមូល និងរៀបចំដាក់ជាគំនរ ដើម្បីសហការជាមួយរដ្ឋបាលព្រៃឈើចុះធ្វើការវាស់វែង និងត្រូវបង់ថ្លៃសួយសារ និងបុព្វលាភជូនរដ្ឋតាមនីតិវិធីមុននឹងយកទៅប្រើប្រាស់ ។

សម្រាប់អនុតំបន់ដែលបានទទួលគោលការណ៍អនុញ្ញាតពី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឱ្យឈូសឆាយមុនប្រកាសនេះចូលជាធរមាន អាចបន្តអនុវត្តទៅតាមគោលការណ៍ដែលបានសម្រេចរួចហើយនោះ ។

**ប្រការ២** : អគ្គលេខាធិការ អគ្គនាយក នាយកខុទ្ទកាល័យ ប្រធានអង្គភាព ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១០

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**ចាន់ សារុន**

**កន្លែងទទួល** :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-គ្រប់ក្រសួង ស្ថាប័នកណ្តាល
-ដូចប្រការ២
-គ្រប់សាលាខេត្ត-រាជធានី
-ឯកសារ-កាលប្បវត្តិ